01471815

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 09 / 05 / 2017
ម៉ោង (Time/Heure): 13:30
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

សាធារណៈ / Public

# អង្គជំនុំជម្រះសាលាដំបូង

ថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០១៧

**ជូនចំពោះ៖** ភាគីទាំងអស់នៃសំណុំរឿង ០០២

**ពី៖** ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង

**ចម្លងជូន៖** លោក/លោកស្រីចៅក្រម និង មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង

**កម្មវត្ថុ៖** ការទទួលយកកំណត់ហេតុនៃការស្តាប់ចម្លើយដែលបានដាក់បង្ហាញថ្មីៗ ពីក្នុងសំណុំរឿង ០០៤ របស់សាក្សីដែលបានផ្តល់សក្ខីកម្មនៅក្នុងអំឡុងកិច្ចដំណើរការនៃនីតិវិធីជំនុំជម្រះនៅក្នុងសំណុំរឿង ០០២

១. នៅថ្ងៃទី ០១ ខែ ឧសភា ឆ្នាំ ២០១៧ សហព្រះរាជអាជ្ញាអន្តរជាតិបានផ្ញើអ៊ីម៉ែលមកកាន់អង្គជំនុំជម្រះសាលាដំបូង ស្នើអង្គជំនុំជម្រះសុំការអនុញ្ញាតពីសហចៅក្រមស៊ើបអង្កេត ក្នុងការដាក់បង្ហាញកំណត់ហេតុនៃការស្តាប់ចម្លើយជាលាយលក្ខណ៍អក្សរចំនួនពីរ (កំណត់ហេតុនៃការស្តាប់ចម្លើយ) ពីក្នុងសំណុំរឿង ០០៤ របស់សាក្សីដែលបានមកផ្តល់សក្ខីកម្មនៅក្នុងអំឡុងកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្នុងសំណុំរឿង ០០២/០២។ តាមរយៈអ៊ីម៉ែល នៅថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០១៧ អង្គជំនុំជម្រះសាលាដំបូងបានស្នើសុំការអនុញ្ញាតពីសហចៅក្រមស៊ើបអង្កេតអន្តរជាតិ (ស.ច.ស.អ.) ក្នុងការដាក់បង្ហាញកំណត់ហេតុនៃការស្តាប់ចម្លើយទាំងពីរនេះ (ឯកសារ E319/69.2)។ ស.ច.ស.អ. បានអនុញ្ញាតឱ្យដាក់បង្ហាញកំណត់ហេតុនៃការស្តាប់ចម្លើយទាំងពីរនេះនៅក្នុងសេចក្តីសម្រេចមួយ ចុះនៅថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ ២០១៧

(សំណុំរឿង ០០៤ ឯកសារ D193/107)។

២. អង្គជំនុំជម្រះសាលាដំបូងសូមរម្លឹកអំពីការអនុវត្តរបស់ខ្លួន ក្នុងការទទួលយកធ្វើជាភ័ស្តុតាងនូវរាល់ចម្លើយពីមុនរបស់ដើមបណ្តឹងរដ្ឋប្បវេណី ឬ សាក្សី ដែលបានមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ អនុលោមតាមវិធាន ៨៧(៣) និង ៨៧(៤) នៃវិធានផ្ទៃក្នុង។ ដើម្បីជាប្រយោជន៍នៃការស្វែងរកការពិត អង្គជំនុំជម្រះនិងភាគីអាចចូលពិនិត្យមើលរាល់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សីដែលនឹងត្រូវមកផ្តល់សក្ខីកម្មនៅក្នុងសំណុំរឿង ០០២/០២ គឺជា (ឯកសារ E421/4 កថាខណ្ឌ ១២)។ អង្គជំនុំជម្រះសូមបញ្ជាក់ថា ការអនុវត្តនេះក៏ត្រូវបានប្រើប្រាស់ចំពោះចម្លើយរបស់សាក្សី ដែលបានធ្វើឡើងបន្ទាប់ពីសាក្សីនោះបានមកផ្តល់សក្ខីកម្មរួចហើយផងដែរ ដើម្បីឱ្យអង្គជំនុំជម្រះ និងភាគីអាចធ្វើការវាយតម្លៃបានពេញលេញចំពោះភាពជឿជាក់បាន ដោយផ្អែកទៅលើថា តើចម្លើយរបស់សាក្សីទាំងនោះស៊ីសង្វាក់គ្នាដល់កម្រិតណា។ ហេតុដូច្នេះ ដើម្បីជាប្រយោជន៍នៃការស្វែងរកការពិត អង្គជំនុំជម្រះសម្រេចទទួលយកធ្វើជាឯកសារភ័ស្តុតាងនូវចម្លើយរបស់សាក្សី ដែលបានធ្វើឡើងបន្ទាប់ពីបានមកផ្តល់សក្ខីកម្មរួចហើយ។

៣. អង្គជំនុំជម្រះសាលាដំបូងកត់សម្គាល់ថា ស.ច.ស.អ. បានរៀបចំកំណត់ហេតុនៃការស្តាប់ចម្លើយទាំងពីរនេះ បន្ទាប់ពីសាក្សីទាំងនេះបានមកផ្តល់សក្ខីកម្មក្នុងសំណុំរឿង ០០២/០២ ។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះសម្រេចទទួលយកកំណត់ហេតុនៃការស្តាប់ចម្លើយចំនួនពីរដែលសហព្រះរាជអាជ្ញាអន្តរជាតិបានដាក់បង្ហាញ ធ្វើជាឯកសារភ័ស្តុតាង និងដាក់លេខយោងជា៖ ឯកសារ E3/10803 និង E3/10804 (ឯកសារ E319/69.1)។